01247998

E347/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 06 / 2016
ម៉ោង (Time/Heure) : 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Claudia FENZ**
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

**សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទដកស្រង់មួយ និង ទទួលយកអត្ថបទដកស្រង់ចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន**

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GUIRAUD

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao, Phnom Penh, Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ដោយមេធាវីការពារក្ដី នួន ជា សុំឱ្យ ១) ពិចារណាឡើងវិញលើសេចក្ដីសម្រេច E347/1 របស់អង្គជំនុំជម្រះ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ដែលបានបដិសេធសំណើមួយពីមេធាវីការពារក្ដី ខៀវ សំផន សុំឱ្យទទួលយកជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សដែលមានចំណងជើងថា "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន" ដែលបានចុះផ្សាយនៅខែ មករា ឆ្នាំ ២០១៥ ("របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស") និង ២) ទទួលយកជំពូក III និង IX នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សដដែល អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[1]។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្ដីសន្និដ្ឋានឆ្លើយតបទៅនឹងសំណើនេះទេ។

២. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបដិសេធសំណើនេះ[2]។ តទៅនេះ អង្គជំនុំជម្រះផ្ដល់សំអាងហេតុសម្រាប់សេចក្ដីសម្រេចរបស់ខ្លួន។

## ២. សារណា

៣. មេធាវីការពារក្ដី នួន ជា លើកឡើងថា បទដ្ឋានត្រឹមត្រូវសម្រាប់ការពិចារណាឡើងវិញគ្រប់ដណ្ដប់មិនត្រឹមតែទៅលើភ័ស្ដុតាងថ្មី ឬ កាលៈទេសៈថ្មី ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីពេលមុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើស្ថានភាពដែលសេចក្ដីសម្រេចពីមុនមានកំហុស ឬ បណ្ដាលឱ្យមានភាពអយុត្តិធម៌។ បទដ្ឋានទូលំទូលាយសម្រាប់ការពិចារណាឡើងវិញនេះត្រូវបានអង្គបុរេជំនុំជម្រះប្រកាន់យក និង ត្រូវបានអនុវត្តជាទូទៅនៅតុលាការ ICTY[3]។ មេធាវី

---

[1] សំណើរបស់ នួន ជា សុំឱ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទសង្ខេបមួយ និង ទទួលយកអត្ថបទចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន" ឯកសារ E347/2 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ១ ("សំណើ")។

[2] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទដកស្រង់មួយ និង ទទួលយកអត្ថបទដកស្រង់ចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន" ឯកសារ E347/3 ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ២។

[3] សំណើ កថាខណ្ឌ ១២-១៣។

ការពារក្តី នួន ជា លើកឡើងថា កំហុសច្បាស់លាស់មួយរបស់អង្គជំនុំជម្រះ ព្រមទាំងការប្រែប្រួលនៃកាលៈទេសៈ តម្រូវឱ្យមានការពិចារណាឡើងវិញទៅលើសេចក្តីសម្រេច E347/1[4]។ មេធាវីការពារក្តី លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តបទដ្ឋានមួយដ៏តឹងរ៉ឹងដោយធ្វើការវាយតម្លៃស៊ីជម្រៅទៅលើតម្លៃជាភ័ស្តុតាងនៃជំពូក II នៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ទោះបីជាវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រឹមតែតម្រូវឱ្យមានការវាយតម្លៃពីភាពជាប់ពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន *តាមការវិភាគបឋម* ប៉ុណ្ណោះនោះ[5]។ ទាក់ទិននឹងការប្រែប្រួលកាលៈទេសៈ មេធាវីការពារក្តីលើកឡើងថា ការផ្អាកការស្តាប់សក្ខីកម្មសាក្សីលើប្រធានបទស្តីពីការប្រព្រឹត្តិទៅលើជនជាតិចាម ការស្តាប់របស់សាក្សីឈ្មោះ ជា ស៊ីម នៅខែ មិថុនា ឆ្នាំ ២០១៥ និង ការរង់ចាំការចេញសេចក្តីសម្រេចលើសំណើសុំ E370 របស់ខ្លួនដែលសុំស្តាប់សក្ខីកម្មសាក្សីលើប្រធានបទដដែលនោះ បានកាត់បន្ថយឱកាសរបស់មេធាវីការពារក្តីក្នុងការសួរដេញដោលសាក្សី និង បានប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការការពារក្តី។ មេធាវីការពារក្តីក៏លើកឡើងផងដែរថា ទឡ្ហីករណ៍របស់ខ្លួនក្នុងការគាំទ្រដល់ការទទួលយកជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានភាពខុសគ្នាយ៉ាងខ្លាំង និង មានភាពលម្អិតជាងទឡ្ហីករណ៍នានាដែលបានលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន[6]។

៤. មេធាវីការពារក្តី នួន ជា ក៏បានលើកឡើងដែរថា ជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានបំពេញលក្ខខណ្ឌតម្រូវនៃភាពជាប់ពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន*តាមការវិភាគបឋម* ដែលមានចែងក្នុងវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយសាររបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សត្រូវបានចុះផ្សាយនៅខែ មករា ឆ្នាំ ២០១៥ ក្រោយពេលចាប់ផ្តើមការជំនុំជម្រះ និង បានផ្តល់នូវភ័ស្តុតាងដែលអាចជឿជាក់បាន និង ស្របគ្នា ដែលលើកឡើងថាកងទ័ពក្រោមបញ្ជារបស់ ហ៊ុន សែន បានជាប់ពាក់ព័ន្ធនឹងការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅកោះផល និង ស្វាយឃ្លាំង។ ចុងក្រោយ មេធាវីការពារក្តី នួន ជា លើកឡើងថា ជំពូក II គួរត្រូវបានទទួលយកដើម្បីជាប្រយោជន៍នៃយុត្តិធម៌ដោយសារជំពូកនេះអាចជាភ័ស្តុតាងដោះបន្ទុក

[4] សំណើ កថាខណ្ឌ ១៥។

[5] សំណើ កថាខណ្ឌ ១៦។

[6] សំណើ កថាខណ្ឌ ១៧-១៩។

សម្រាប់ នួន ជា ដោយសារភ័ស្តុតាងនេះបង្ហាញថា អង្គភាពយោធាភូមិភាគបូព៌ាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាមនៅស្វាយឃ្លាំង[7]។

៥. មេធាវីការពារក្តី នួន ជា ស្នើសុំបន្ថែមទៀតឱ្យទទួលយកជាភ័ស្តុតាងនូវជំពូក III និង IX នៃរបាយការណ៍ ដែលមានចំណងជើងថា "ហ៊ុន សែន និង កម្មវិធីការងារដោយបង្ខំ "ក៥"" និង "ហ៊ុន សែន និង វិទ្ធង្សនាសាលាក្តីខ្មែរក្រហម" អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីអះអាងថា សំណើនេះត្រូវបានដាក់ទាន់ពេលវេលា ហើយថា ជំពូកទាំងពីរពិភាក្សាពីបញ្ហានានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។ មេធាវីការពារក្តីលើកឡើងថា ជំពូក III ផ្តល់ព័ត៌មានពាក់ព័ន្ធដែលអាចជួយអង្គជំនុំជម្រះក្នុងការស្វែងរកការពិត ទាក់ទិននឹងការអនុវត្តកម្មវិធី ក៥ ដែលបានប្រព្រឹត្តដោយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ១៩៨៤-១៩៨៩។ បើតាមមេធាវីការពារក្តី នួន ជា ប្រជាជនកម្ពុជារាប់ពាន់នាក់បានស្លាប់ ក្នុងអំឡុងពេលសាងសង់បន្ទាយការពារនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ហើយការស្លាប់ទាំងនេះត្រូវតែដកចេញពីការស្លាប់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[8]។ មេធាវីការពារក្តី នួន ជា លើកឡើងថា ជំពូក IX ពិភាក្សាពីការបង្អាក់របស់ ហ៊ុន សែន និង ការប្រើប្រាស់ឥទ្ធិពលមិនត្រឹមត្រូវមកលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ មេធាវីការពារក្តីអះអាងថា សេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សមានសារៈសំខាន់ជាខ្លាំង សម្រាប់សំណុំ-រឿង ០០២/០២ ដោយសារវាផ្តល់មូលហេតុចម្បងនៃការព្រួយបារម្ភអំពីភាពមិនលម្អៀង និងឯករាជ្យភាពរបស់អង្គជំនុំជម្រះសាលាដំបូង និង លទ្ធភាពរបស់ខ្លួនក្នុងការការពារសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[9]។ ចុងក្រោយ មេធាវីការពារក្តី នួន ជា លើកឡើងថា ជំពូក III និង IX ត្រូវតែទទួលយក ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ដោយសារជំពូក III គឺជាភ័ស្តុតាងដោះបន្ទុក ហើយជំពូក IX មានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីមិនឱ្យមានភាព

[7] សំណើ កថាខណ្ឌ ២០-២៣។

[8] សំណើ កថាខណ្ឌ ២៥-២៦។

[9] សំណើ កថាខណ្ឌ ២៨-២៩ យោងផងដែរដោយពាក្យសុំ E314/6 របស់ខ្លួន។

អយុត្តិធម៌[10]។

### ៣. ច្បាប់ជាធរមាន

៦. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងទាំងអស់ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍ក្នុងការស្វែងរកការពិត នៅគ្រប់ដំណាក់-កាលជំនុំជម្រះ ឱ្យតែភ័ស្តុតាងនោះបំពេញតាមបទដ្ឋាននៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង មានយថាភាព*តាមការវិភាគបឋម* ដែលជាលក្ខខណ្ឌនៅក្នុងវិធាន ៨៧(៣)។ អង្គជំនុំជម្រះសម្រេចលើខ្លឹមសារនៃពាក្យសុំឱ្យទទួលយកជាភ័ស្តុតាង អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យនានានៅក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏តម្រូវផងដែរថា ភាគីដែលបានស្នើសុំត្រូវបញ្ជាក់ពីមូល-ហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬ ភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបានទេនៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភ័ស្តុតាងដែលមិនបំពេញទៅនឹងលក្ខណៈវិនិច្ឆ័យនេះទាំងស្រុងទេ រួមទាំងក្នុងករណីដែលភ័ស្តុតាងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងអស់រួមគ្នា និង ក្នុងករណីដែលឯកសារដែលស្នើសុំនោះជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យមានការវាយតម្លៃដើម្បីចៀសវាងភាពអយុត្តិធម៌[11]។

---

[10] សំណើ កថាខណ្ឌ ២៧, ៣០។

[11] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំស្តាប់សក្ខីកម្មសាក្សីបន្ថែមមួយរូបលើអង្គហេតុស្តីពីការដ្ឋានការងារទំនប់ត្រពាំងថ្ម" ឯកសារ E368/1 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ៣ និង អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ និង សេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤" ឯកសារ E319/7 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៨។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យទទួលយកចម្លើយសាក្សីចំនួនប្រាំមួយ និង ឧបសម្ព័ន្ធមួយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤)" ឯកសារ E319/30/1 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ២ និង ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E376, E376/1) ឯកសារ E276/2 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

## ៤. សម្អាងហេតុ

### ៤.១ "ការពិចារណាឡើងវិញ" ទៅលើសេចក្តីសម្រេចពាក់ព័ន្ធនឹងជំពូក II

៧. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា ទាំងច្បាប់កម្ពុជា ដែលជាប្រភពចម្បងនៃច្បាប់នីតិវិធីជាធរមាន នៅ អ.វ.ត.ក ទាំងវិធានផ្ទៃក្នុង ដែលមានគោលបំណងចងក្រងនូវនីតិវិធីជាធរមាននៅកម្ពុជា និង ដើម្បីធានាថា ក្របខណ្ឌនីតិវិធីជាធរមាននៅ អ.វ.ត.ក មានភាពទូលំទូលាយ និង ស្របទៅនឹង បទដ្ឋានអន្តរជាតិ[12] មិនបានចែងថា អង្គជំនុំជម្រះអាចពិចារណាឡើងវិញទៅលើសេចក្តីសម្រេច របស់ខ្លួននោះឡើយ។ អង្គជំនុំជម្រះយល់ឃើញថា ដំណោះស្រាយតែមួយគត់ទៅតាមក្របខណ្ឌ ច្បាប់នៅ អ.វ.ត.ក ចំពោះការចោទប្រកាន់ថាមានកំហុសក្នុងការផ្តល់សំអាងហេតុនៅក្នុងសេចក្តី សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រូវប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល។ មេធាវី ការពារក្តី នួន ជា យោងទៅដល់យុត្តិសាស្ត្រអន្តរជាតិ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានសិទ្ធិអំណាចក្នុងការពិចារណាឡើងវិញបាន។ ដូច មានចែងក្នុងកិច្ចព្រមព្រៀង[13] អង្គជំនុំជម្រះអាចស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលបាន បង្កើតឡើងនៅកម្រិតអន្តរជាតិតែនៅក្នុងកាលៈទេសៈដែលត្រូវបានកម្រិតយ៉ាងតឹងរ៉ឹង ដូចជា នៅ ពេលនីតិវិធី ដែលមានស្រាប់មិនដោះស្រាយបញ្ហាណាមួយ ឬ នៅពេលដែលមានបញ្ហាស្តីពីភាព ស្រប ឬ មិនស្របទៅនឹងបទដ្ឋានអន្តរជាតិនោះ។ នៅក្នុងករណីនេះ អង្គជំនុំជម្រះយល់ឃើញថា ពុំ

---

[12] *សូមមើល* បុព្វកថានៃវិធានផ្ទៃក្នុង កថាខណ្ឌចុងក្រោយ៖ *"[...] ជំនុំជម្រះវិសាមញ្ញបានអនុម័តវិធានផ្ទៃក្នុង ដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ដោយអនុលោមតាមមាត្រា ២០ថ្មី ២៣ថ្មី និង មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការ បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅ ពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់ លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬ ក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិ នៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ"*។

[13] *សូមមើល* មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង អ.វ.ត.ក)។ *សូម មើលផងដែរ* មាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើវិសោធនកម្ម។

ចាំបាច់ស្វែងរកការណែនាំបែបនេះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា ភាពឆាប់រហ័សនៃការជំនុំជម្រះ និងសុវត្ថិភាពគតិយុត្ត គឺស្ថិតក្នុងចំណោមគោលការណ៍ជាសារវ័ន្ត ដែលជាមគ្គុទ្ទេសន៍សម្រាប់អ្នករៀបរៀងសេចក្តីព្រាងវិធានផ្ទៃក្នុង[14]។ ក្នុងការបង្កើតក្របខណ្ឌនីតិវិធីដើម្បីជួយសម្រួលឱ្យដំណើរការជំនុំជម្រះមានភាពរលូន និង ឆាប់រហ័ស អ្នករៀបរៀងសេចក្តីព្រាងវិធានផ្ទៃក្នុងបានជ្រើសរើសបញ្ចូលនូវការកម្រិតតឹងរ៉ឹងនានាពាក់ព័ន្ធនឹងការប្តឹងសាទុក្ខភ្លាមៗចំពោះសេចក្តីសម្រេចបាន[15]។ វិធីសាស្ត្រនេះគឺផ្ទុយពីវិធីសាស្ត្រដែលត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌច្បាប់នៃតុលាការ *មិនអចិន្ត្រៃយ៍*។ ការអនុញ្ញាតឱ្យមានការពិចារណាឡើងវិញទៅតាមសំណើរបស់មេធាវីការពារក្តីនឹងមិនស្របទៅនឹងក្របខណ្ឌនីតិវិធីពិសេសសម្រាប់ អ.វ.ត.ក ទេ ដោយសារវានឹងបង្កឱ្យមានភាពមិនប្រាកដនៅក្នុងនីតិវិធីដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះ និងបណ្តាលឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធីដែលមិនចាំបាច់ ដោយសារអង្គជំនុំជម្រះអាចនឹងត្រូវបង្ខំឱ្យពិនិត្យទៅលើសេចក្តីសម្រេចរបស់ខ្លួនឡើងវិញមិនចេះអស់មិនចេះហើយ ហេតុនេះវាផ្ទុយទៅនឹងការធានាឱ្យមានភាពឆាប់រហ័ស និង ភាពយុត្តិធម៌ ដែលអ្នករៀបរៀងសេចក្តីព្រាងវិធានផ្ទៃក្នុងមានបំណងការពារ។ ដូច្នេះ ស្របទៅនឹងយុត្តិសាស្ត្រដែលខ្លួនបានបង្កើតឡើង អង្គជំនុំ-ជម្រះបដិសេធសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ទាក់ទិននឹងចំណុចនេះ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះអាចពិចារណាទៅលើសំណើថ្មីដែល "សំណើជាថ្មីនោះមានភស្តុតាងថ្មី ឬកាលៈទេសៈថ្មី"[16] ដែលនឹងនាំឱ្យមានសេចក្តីសម្រេចថ្មី ដោយផ្អែកលើភស្តុតាង ឬ កាលៈទេសៈ

---

[14] បទប្បញ្ញត្តិទាំងអស់នៃក្របខណ្ឌច្បាប់នៅ អ.វ.ត.ក និង ជាពិសេសវិធានផ្ទៃក្នុង *"[...] ត្រូវតែបកស្រាយក្នុងន័យ [...] ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់ជំនុំជម្រះវិសាមញ្ញ [...]"*។ បន្ថែមទៀត អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលរៀបរាប់នូវគោលការណ៍ជាសារវ័ន្ត "*ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប*"។ សូមមើលវិធាន ២១(១) និង (៤) នៃវិធានផ្ទៃក្នុង។

[15] សូមមើលវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[16] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឱ្យពិចារ-ណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២" ឯកសារ E314/5/3 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចទាក់ទងនឹងការទទួលយកសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ដែលទើបរកបានថ្មីៗ (ឯកសារ E282/2/1) និង ចម្លើយតបរបស់ ខៀវ សំផន *សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទដកស្រង់មួយ និង ទទួលយកអត្ថបទដកស្រង់ចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំនៃការកាន់តំណែងរបស់ហ៊ុន សែន - សាធារណៈ* -ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦

ថ្មីទាំងនោះ។

៨. នាពេលនេះ អង្គជំនុំជម្រះនឹងវាយតម្លៃថាតើ មេធាវីការពារក្តី នួន ជា បានបង្ហាញឯកសារថ្មីផ្សេងទៀត ឬ កាលៈទេសៈថ្មី ដែលធ្វើយុត្តិកម្មដល់ការទទួលយកជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សជាភ័ស្តុតាងដែរ ឬ យ៉ាងណា។ អង្គជំនុំជម្រះសន្និដ្ឋានថា មេធាវីការពារក្តី នួន ជា ពុំបានបង្ហាញថាតើការស្លាប់របស់សាក្សី ជា ស៊ីម ការរៀបចំកាលវិភាគថ្មីដើម្បីកោះហៅសាក្សី ឬ ការពន្យារការចេញសេចក្តីសម្រេចមួយលើបញ្ហានានាដែលទាក់ទិននឹងការប្រព្រឹត្តិចំពោះជនជាតិចាម បង្កើតបានជាកាលៈទេសៈថ្មីដែលផ្តល់យុត្តិកម្មដល់សេចក្តីសម្រេចថ្មីលើបញ្ហានេះដោយរបៀបណាទេ។ ទាក់ទិននឹងបញ្ហាពីរចុងក្រោយនេះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីអំពីសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំ E370[17] និង បានស្តាប់ភ័ស្តុតាងពាក់ព័ន្ធនឹងប្រធានបទនេះគ្រប់គ្រាន់ហើយ។ មេធាវីការពារក្តី នួន ជា ពុំបានបង្ហាញថា ទឡ្ហីករណ៍របស់ពួកគេមានភាពខុសគ្នាខ្លាំងទៅនឹងទឡ្ហីករណ៍នានាដែលបានលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន

---

(ឯកសារ E282/2/1/1) ឯកសារ E282/2/1/2 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើបន្ទាន់របស់ ខៀវ សំផន ដែលសុំការបំភ្លឺអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃចម្លើយ និង ប្រតិចារឹកសវនាការ (E299/1) ឯកសារ E299/2 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម" ឯកសារ E238/11/1 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៧-៨ និង អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកុំផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយលើកមុន ទាក់ទិននឹងទួលពោធិ៍ជ្រៃ ដល់សាក្សីនៅមុនការផ្តល់សក្ខីកម្ម (ឯកសារ E292/2) ឯកសារ E292/2/1 ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។

[17] *សូមមើល* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពន្លឿនការកោះហៅសាក្សីពីររូបដែលបានស្នើសុំរួចហើយ និង សុំឱ្យកោះហៅសាក្សីបន្ថែមនៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ ជនជាតិចាម (សំអាងហេតុពេញលេញនឹងចេញនៅពេលក្រោយ) ឯកសារ E370/3 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ និង អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យពន្លឿនការកោះហៅសាក្សីពីររូបដែលបានស្នើសុំរួចហើយ និង សុំឱ្យកោះហៅសាក្សីបន្ថែមនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម និង លើសំណើរបស់សហព្រះរាជអាជ្ញាជាតិសុំឱ្យទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ជំនួសការចូលបង្ហាញខ្លួនដោយផ្ទាល់នៅតុលាការ" ឯកសារ E370/4 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦។

នៅក្នុងសំណើដើមរបស់ខ្លួនទេ។ ទោះបីមានភាពក្បោះក្បាយ និងលម្អិតជាងក៏ដោយ តែទឡ្ហីករណ៍របស់មេធាវីការពារក្តី នួន ជា មានខ្លឹមសារស្រដៀងទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី ខៀវ សំផន ត្រង់ចំណុចថា ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានលើកឡើងស្រដៀងគ្នាថាជំពូក II មានភ័ស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់ពីការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅឆ្នាំ១៩៧៥ នៅភូមិភាគបូព៌ាហេតុនេះហើយ ជំពូកនេះគួរតែត្រូវបានទទួលយកជាភ័ស្តុតាង អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។

៩. ដោយសារពុំមានភ័ស្តុតាងថ្មី ឬ កាលៈទេសៈថ្មី អង្គជំនុំជម្រះបដិសេធសំណើសុំពិចារណាសាជាថ្មីទៅលើការទទួលយកជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សធ្វើជាភ័ស្តុតាង។

## ៤.២ <u>សំណើតាមវិធាន ៨៧(៤) ទាក់ទិននឹងជំពូក III និង IX</u>

១០. ជាបញ្ហាបឋមទាក់ទិននឹងសំណើសុំឲ្យទទួលយកជំពូក III និង IX នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សំណើនេះមិនត្រូវបានដាក់ទាន់ពេលវេលាទេ។ ទោះបីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចុះផ្សាយក្រោយពេលចាប់ផ្តើមជំនុំជម្រះក៏ដោយ តែរបាយការណ៍នេះមានសម្រាប់សាធារណៈជនចាប់តាំងពីបានចុះផ្សាយនៅខែមករា ឆ្នាំ ២០១៥ មកម្ល៉េះ។ ក្នុងរយៈពេលប្រហែល ១១ ខែ ចន្លោះពីពេលចុះផ្សាយរបាយការណ៍នេះ និង ការដាក់សំណើនេះ មេធាវីការពារក្តី នួន ជា ពុំបានដាក់សំណើរបស់ខ្លួនផ្ទាល់ ឬ ក៏មិនបានបញ្ចេញប្រតិកម្មទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលសុំឲ្យទទួលយកមួយផ្នែកតូចនៃរបាយការណ៍នេះទេ។ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា មេធាវីការពារក្តី នួន ជា គួរបានដឹងពីភាពពាក់ព័ន្ធនៃជំពូក III និង IX ហើយហេតុនេះ ពុំបានបំពេញការងារដោយយកចិត្តទុកដាក់ក្នុងការដាក់សំណើឲ្យបានទាន់ពេលវេលាទេ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងនឹងវាយតម្លៃថាតើវាជាប្រយោជន៍នៃយុត្តិធម៌ដែរ ឬ ទេ ក្នុងការទទួលយកជំពូក III និង IX នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សនោះ។

១១. ជំពូក III ដែលមានចំណងជើងថា "ហ៊ុន សែន និង កម្មវិធីការងារដោយបង្ខំ "ក៥"" ពិពណ៌នាពីកម្មវិធី ក៥ ត្រូវបានអះអាងថាមានជាប់ពាក់ព័ន្ធនឹង "ការធ្វើកំណែនប្រជាជនស៊ីវិលកម្ពុជាទ្រង់-ទ្រាយធំឲ្យទៅធ្វើការនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង ដែលបានបណ្តាលឲ្យមានការស្លាប់

ប្រជាជនកម្ពុជារាប់ពាន់នាក់ដោយសារជំងឺ និង គ្រាប់មីន"[18]។ ទោះបីអង្គជំនុំជម្រះទទួលស្គាល់ថា កម្មវិធីដែលបានលើកឡើងអាចបណ្តាលឲ្យមានការស្លាប់ជាទ្រង់ទ្រាយធំក៏ដោយ តែអង្គជំនុំជម្រះសង្កេតឃើញថា ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងនៅឆ្នាំ ១៩៨៤-១៩៨៩ ជាពេលវេលាដែលមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា សេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ទាក់ទិននឹងការចោទប្រកាន់ពីចំនួនមនុស្សស្លាប់ដែលកម្មវិធី ក៥ បានបង្កដោយផ្ទាល់នោះ គឺពុំមានប្រភពច្បាស់លាស់ទេ[19]។ អង្គជំនុំជម្រះសន្និដ្ឋានថា ដោយសារការប៉ាន់ប្រមាណពីចំនួនមនុស្សស្លាប់ដោយសារការអនុវត្តកម្មវិធី ក៥ ពុំមានមូលដ្ឋានសំអាងច្បាស់លាស់ ដូចនេះវាមិនសមស្របក្នុងការបង្ហាញពីភាពខុសគ្នាដែលអាចជឿជាក់បានរវាងការស្លាប់ទាំងនេះ និង ការស្លាប់ដែលបង្កឡើងដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។

១២. ជំពូក IX ទាក់ទិននឹងការចោទប្រកាន់ពីការជ្រៀតជ្រែករបស់រដ្ឋាភិបាល និង ការចោទប្រកាន់ពីភាពលម្អៀងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ដែលមេធាវីការពារក្តី នួន ជា បានលើកឡើងថា វាផ្តល់ជាមូលហេតុចម្បងក្នុងការព្រួយបារម្ភអំពីភាពមិនលម្អៀង និង ឯករាជ្យភាពរបស់អង្គជំនុំជម្រះសាលាដំបូង។ ទាក់ទិននឹងចំណុចនេះ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា ពុំបានធ្វើការចោទប្រកាន់ជាក់លាក់ទាក់ទិននឹងរឿងក្តីនេះទេ ៖ ការចោទប្រកាន់ពីការជ្រៀតជ្រែកដោយយោងទៅដល់ឧបសគ្គនានានៅក្នុងការស៊ើបអង្កេតនៃសំណុំរឿង ០០៣ និង ០០៤។ ហេតុនេះ អង្គជំនុំជម្រះយល់ថា ជំពូក IX ពុំបានបង្ហាញពីការប៉ះពាល់ជាក់ស្តែងនៃការចោទប្រកាន់ពីការជ្រៀតជ្រែកទៅក្នុងរឿងក្តីនេះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះរម្លឹកថា នីតិវិធីសម្រាប់ជំទាស់ទៅនឹងភាពមិនលម្អៀង និង ឯករាជ្យភាពរបស់ចៅក្រម មានកំណត់ក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា ធ្លាប់បានដាក់ពាក្យសុំអនុលោមតាមវិធាន ៣៤ ក្នុងរឿងក្តីនេះ ហើយថា ពាក្យសុំនោះត្រូវបានបដិសេធដោយ

---

[18] របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ទំព័រ ២២។

[19] *សូមមើល* របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ទំព័រ ២៥។

សេចក្តីសម្រេចដែលមានសម្លេងភាគច្រើន[20]។ ហេតុនេះ អង្គជំនុំជម្រះយល់ថា ជំពូក IX ពុំមានព័ត៌មានពាក់ព័ន្ធដែលអាចជួយអង្គជំនុំជម្រះក្នុងការស្វែងរកការពិតក្នុងសំណុំរឿង ០០២/០២ ទេ។

**តាមសំអាងហេតុនានាខាងលើ អង្គជំនុំជម្រះសាលាដំបូង សម្រេច៖**

**បដិសេធ** សំណើថ្មីសុំឲ្យទទួលយកជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

**បដិសេធ** សំណើសុំឲ្យទទួលយកជំពូក III និង IX នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

ភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C * C.E.T.C

**និល ណុន**

---

[20] *សូមមើល* អង្គជំនុំជម្រះសាលាដំបូង “សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង” ឯកសារ E314/12 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ និង អង្គជំនុំជម្រះសាលាដំបូង “សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត” ឯកសារ E314/12/1 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥។